ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

លេខ ពណសហអ

គោរពជូន

លោកប្រធាននាយកដ្ឋានរដ្ឋបាល

កម្មវត្ថុ : សំណើសុំអញ្ជើញសមាជិកគណៈកម្មការអនុវត្តន៍ (IC) ចូលរួមប្រជុំ និងស្នើសុំបន្ទប់ប្រជុំ ១ ព្រមទាំងផ្កា។

យោង : សេចក្តីសម្រេចលេខៈ ៧៦ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩។

ភ្ជាប់ជូនៈ របៀបវារៈ និងឯកសារពិភាក្សា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថាៈ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នឹងធ្វើការសម្របសម្រួល និងរៀបចំកិច្ចប្រជុំខាងលើ ដើម្បី**ពិនិត្យ, វាយតម្លៃ និងសម្រេចលើគម្រោង យុទ្ធសាស្ត្រមួយចំនួនដែលបានស្នើនៅក្នុងរបាយការណ៍នៃ Mid Term Review និងឱ្យសម្រេចបានតាមការកំណត់ក្នុងគម្រោង TDSP ដោយអនុម័តឱ្យបានយ៉ាងហោចណាស់ច្រើនជាង១ នៅដំណាច់ខែ ឧសភា នេះ រួចស្នើមកសុំការគាំទ្រផ្នែក ហិរញ្ញវត្ថុមុននឹងដាក់ជូនអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងទៅនឹងពាណិជ្ជកម្ម (SSC-TD-TRI) ដើម្បីសម្រេច និងអនុវត្តន៍**។

កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១ វេលាម៉ោង ០៨:៣០ នៅក្រសួងពាណិជ្ជកម្ម** ក្រោមអធិបតីភាពឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការវត្តន៍ (IC) ។ ឯកឧត្តម លោកជំទាវ លោក និងលោកស្រី ដែលត្រូវអញ្ជើញចូលរួមមានៈ

- **លោកជំទាវ តឹករ៉េត កំរង** អនុរដ្ឋលេខាធិការ និងជាសមាជិកនៃគណៈកម្មការអនុវត្តន៍
- **ឯកឧត្តម វេង សុធី** អនុរដ្ឋលេខាធិការ និងជាសមាជិកនៃគណៈកម្មការអនុវត្តន៍
- **ឯកឧត្តម កាន ច័ន្ទមេត្តា** អនុរដ្ឋលេខាធិការ និងជាសមាជិកនៃគណៈកម្មការអនុវត្តន៍
- **ឯកឧត្តម ឯម សោភ័ណ្ឌ** អនុរដ្ឋលេខាធិការ និងជាសមាជិកនៃគណៈកម្មការអនុវត្តន៍
- **ឯកឧត្តម ឱក ទីណា** អនុរដ្ឋលេខាធិការ និងជាសមាជិកនៃគណៈកម្មការអនុវត្តន៍
- **ឯកឧត្តម សុខ សុភ័ក្ត្រ** អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ និងជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការអនុវត្តន៍
- **ឯកឧត្តម ឃឹម សេរីវង្ស** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារសរសរស្តម្ភទី៣
- **លោក ហង់ សុជីវិន** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជាលេខាធិការ

អាស្រ័យហេតុនេះ សូមលោកប្រធាន ជួយសម្រួលអញ្ជើញសមាជិកខាងលើ, បន្ទប់ប្រជុំ១ និងផ្កា ដោយក្តីអនុគ្រោះ។

សូមលោកប្រធាន ទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឧសភា ឆ្នាំ ២០១១

ប្រធាន